**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តឧត្តរមានជ័យ**
សំណុំរឿងព្រហ្មទណ្ឌលេខ: ២៥៦
ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១
សាលក្រមលេខ: **៣៩(ក)/១០៩**
ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តឧត្តរមានជ័យ

បានបើកសវនាការជាសាធារណៈ នៅសាលជម្រះក្ដីនៃសាលាដំបូងខេត្តឧត្តរមានជ័យ
នាថ្ងៃ អង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ប្រាំបួន និង សាមសិប នាទី ព្រឹក មានសមាសភាពដូចតទៅ៖

## សមាសភាពចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សា
លោកស្រី ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តឧត្តរមានជ័យ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

## មេធាវី

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
លោក ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
លោក ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

<u>ដើម្បីជំនុំជម្រះ</u>៖ លើសំណុំរឿងព្រហ្មទណ្ឌលេខ: <u>២៥៦</u> ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ ។
លើសំណុំរឿងជំនុំជម្រះលេខ: <u>១៤៦</u> ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

ក.ឈ្មោះ [redacted] សុភាព ភេទស្រី កើតឆ្នាំ១៩៨៥ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តឧត្តរមានជ័យ មានទីលំនៅបច្ចុប្បន្នស្ថិតនៅ [redacted] ខេត្តឧត្តរមានជ័យ ប្ដីឈ្មោះ [redacted] សំអាត មានកូនចំនួន០៤នាក់ ឪពុកឈ្មោះ [redacted] ចំរើន (ស្លាប់) ម្ដាយឈ្មោះ [redacted] យន់ (រស់) កម្រិតវប្បធម៌ថ្នាក់ទី៧ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ខ.ឈ្មោះ [redacted] ថារ៉ា ភេទស្រី អាយុ៥៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅ [redacted] ខេត្តឧត្តរមានជ័យ មានទីលំនៅបច្ចុប្បន្នស្ថិត [redacted] ខេត្ត



Scanned with CamScanner

ឧត្តរមានជ័យ ប្តីឈ្មោះ[redacted] ខុយ មានកូនចំនួន០៦នាក់ ឪពុកឈ្មោះ[redacted] ចោង (ស្លាប់) ម្តាយឈ្មោះ[redacted] រឿង (រស់) កម្រិតវប្បធម៌ថ្នាក់ទី៩ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

គ.ឈ្មោះ [redacted] ឡុញ ភេទប្រុស អាយុ៥៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted]សុភន់ មានកូនចំនួន ០៤នាក់ ឪពុកឈ្មោះ [redacted]សេន (ស្លាប់) ម្តាយឈ្មោះ [redacted] ណេ (រស់) កម្រិតវប្បធម៌ថ្នាក់ទី៧ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ឃ.ឈ្មោះ[redacted] ពេក ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តឧត្តរមានជ័យ មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ[redacted] ស្រស់ មានកូនចំនួន០៤នាក់ ឪពុកឈ្មោះ [redacted] ម៉ៃ (ស្លាប់) ម្តាយឈ្មោះ [redacted] យ៉ន (ស្លាប់) កម្រិតវប្បធម៌មិនចេះអក្សរ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ង.ឈ្មោះ [redacted]គក់ ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តឧត្តរមានជ័យ មានទីលំនៅបច្ចុប្បន្នស្ថិតនៅ[redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ[redacted] ធីតា មានកូនចំនួន ០៤នាក់ ឪពុកឈ្មោះ [redacted]ផា (រស់) ម្តាយឈ្មោះ [redacted] ម៉ៅ (ស្លាប់) កម្រិតវប្បធម៌ថ្នាក់ទី៨ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ច.ឈ្មោះ [redacted] លីន ភេទស្រី អាយុ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅ[redacted] ខេត្តឧត្តរមានជ័យ ទីលំនៅបច្ចុប្បន្នស្ថិតនៅ[redacted] ខេត្តឧត្តរមានជ័យ ប្តីឈ្មោះ [redacted] ពុធថា មានកូនចំនួន០៣នាក់ ឪពុកឈ្មោះ [redacted]សាមិត្ត (ស្លាប់) ម្តាយឈ្មោះ[redacted]សាវ៉ាយ (រស់) កម្រិតវប្បធម៌ថ្នាក់ទី៧ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ឆ.ឈ្មោះ [redacted] ញ៉ាន ភេទប្រុស អាយុ៥៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តឧត្តរមានជ័យ មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted]គីមសួរ មានកូនចំនួន០៤នាក់ ឪពុកឈ្មោះ [redacted] កុយ (ស្លាប់) ម្តាយឈ្មោះ [redacted] ព្រឹក (ស្លាប់) កម្រិតវប្បធម៌ថ្នាក់ទី២ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជ.ឈ្មោះ [redacted] ហៀប ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទោកន្លែងកំណើតនៅភូមិ [redacted] ខេត្តឧត្តរមានជ័យ មានទីលំនៅបច្ចុប្បន្នស្ថិតនៅ[redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ[redacted]តុល មានកូនចំនួន០៥នាក់ ឪពុកឈ្មោះ [redacted]ហៀល (ស្លាប់) ម្តាយឈ្មោះ[redacted] ហៀន (រស់) កម្រិតវប្បធម៌ថ្នាក់ទី១ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ឈ.ឈ្មោះ [redacted]វ៉ាត ភេទប្រុស អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តឧត្តរមានជ័យ មានទីលំនៅបច្ចុប្បន្នស្ថិតនៅ[redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted]ពោ មានកូនចំនួន០៥នាក់ ឪពុកឈ្មោះ[redacted] (ស្លាប់) ម្តាយឈ្មោះ អែម (ស្លាប់) កម្រិតវប្បធម៌មិនចេះអក្សរ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ "ក្លែងបន្លំឯកសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ប្រព្រឹត្តនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

## ដើមបណ្តឹងរដ្ឋប្បវេណី

ក.ឈ្មោះ [redacted]ខែម ភេទប្រុស កើតឆ្នាំ១៩៧៣ សញ្ជាតិខ្មែរ មុខរបរ នាយផ្នែករដ្ឋបាលព្រៃឈើសំរោង កើតនៅភូមិស្លក្រាម ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប បច្ចុប្បន្ននៅភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ឪពុកឈ្មោះ [redacted] ប៊ូច (ស្លាប់) ម្តាយឈ្មោះ [redacted]ខន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] សុជាតិ មានកូនចំនួន០៤នាក់ កម្រិតវប្បធម៌ បរិញ្ញាបត្រជាន់ខ្ពស់ ទោសពីមុនគ្មាន ។

## អង្គហេតុដែលបានចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះ

កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ មានការប្រជុំដោះស្រាយវិវាទដីធ្លីនៅសាលប្រជុំនៃសាលាខេត្តឧត្តរមានជ័យ ដោយលោកនាយខណ្ឌរដ្ឋបាលព្រៃឈើបានទៅចូលរួម ។ ក្រោយពីមានការចូលរួមមកគាត់ក៏ទទួលបានឯកសារទាក់ទងបណ្តឹងសុំកិច្ចអន្តរាគមន៍ទៅអភិបាលខេត្តឧត្តរមានជ័យ ពីសំណាក់ប្រជាពលរដ្ឋចំនួន ០៩រូប មាន១.ឈ្មោះ [redacted] សុភាព ភេទស្រី អាយុ៣៧ឆ្នាំ, ២.ឈ្មោះ [redacted] ថាវ៉ា ភេទស្រី អាយុ៥៩ឆ្នាំ, ៣.ឈ្មោះ [redacted]ឡុញ ភេទប្រុស អាយុ៥៦ឆ្នាំ, ៤.ឈ្មោះ [redacted] ពេក ភេទប្រុស អាយុ៥២ឆ្នាំ, ៥.ឈ្មោះ [redacted] គក់ ភេទប្រុស អាយុ៣៧ឆ្នាំ, ៦.ឈ្មោះ [redacted]លីន ភេទស្រី អាយុ៥១ឆ្នាំ, ៧.ឈ្មោះ [redacted] ញ៉ាន ភេទប្រុស អាយុ៥៥ឆ្នាំ, ៨.ឈ្មោះ [redacted]ហៀប ភេទប្រុស អាយុ៤៩ឆ្នាំ និង ៩.ឈ្មោះ [redacted] វ៉ាត ភេទប្រុស អាយុ៥៥ឆ្នាំ ។ ពាក្យបណ្តឹងសុំកិច្ចអន្តរាគមន៍នោះធ្វើឡើង នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ ដោយបណ្តឹងនោះមានភ្ជាប់នូវឯកសារមួយដែលមានចំណងជើងថា គំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយផ្នែករដ្ឋបាលព្រៃឈើសំរោង ។ ចំណុចនេះឈ្មោះ [redacted] ខែម ដែលមានតួនាទីជានាយផ្នែករដ្ឋបាលព្រៃឈើសំរោង តាំងពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ បានសុំធ្វើការបដិសេធថា គំនូសបង្ហាញទីតាំងខាងលើនោះឈ្មោះ [redacted] ខែម មិនបានចេញជូនប្រជាពលរដ្ឋទាំង ០៩រូបនោះទេ ពីព្រោះនៅក្នុងគំនូសបង្ហាញទីតាំងដែលលោក [redacted] ខែម ចេញមានលេខរដ្ឋបាលចេញ-ចូល មានកាលបរិច្ឆេទហត្ថលេខាត្រឹមត្រូវ និងគ្មានឯកសារដើមរក្សាទុកនៅផ្នែករដ្ឋបាលព្រៃឈើសំរោង ។ បើពិនិត្យលើគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផល គូសដោយផ្នែករដ្ឋបាលព្រៃឈើសំរោង គឺបង្ហាញថា គំនូសនេះមានភាពមិនប្រក្រតី ដោយគ្មានកាលបរិច្ឆេទ ហត្ថលេខា និងលេខរដ្ឋបាលត្រឹមត្រូវហើយការសរសេរថា គូសដោយនាយផ្នែករដ្ឋបាលព្រៃឈើសំរោងនោះ មិនមែនជាការពិតទេ ដូចនេះបញ្ជាក់ថាឈ្មោះ [redacted] សុភាព, ឈ្មោះ [redacted] ថាវ៉ា, ឈ្មោះ [redacted] ឡុញ, ឈ្មោះ [redacted]ពេក, ឈ្មោះ [redacted] គក់, ឈ្មោះ [redacted] លីន, ឈ្មោះ [redacted] ញ៉ាន, ឈ្មោះ [redacted] ហៀប និងឈ្មោះ [redacted] វ៉ាត បានធ្វើគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយនាយផ្នែករដ្ឋបាលព្រៃឈើសំរោង នោះជាឯកសារក្លែងក្លាយ និងយកទៅប្រើប្រាស់ជាមួយពាក្យបណ្តឹងសុំកិច្ចអន្តរាគមន៍ ។ ការធ្វើបែបនេះធ្វើឱ្យប៉ះពាល់ដល់តួនាទី ការងារ កត្តិយស និងសេចក្តីថ្លៃថ្នូរ របស់ឈ្មោះ[redacted] ខែម យ៉ាងធ្ងន់ធ្ងរណាស់ រួមទាំងធ្វើឱ្យថ្នាក់លើកើតការមិនទុកចិត្តក្នុងការបំពេញការងាររបស់ឈ្មោះ [redacted]ខែម ថែមទៀត ។

## បានឃើញ

-ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ០០៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ ។



Scanned with CamScanner

-ដីកាសន្និដ្ឋានស្ថាពរលេខ: ១២៧ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ។

-ដីកាដំណោះស្រាយលេខ: ១១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ ។

-ការផ្តល់ និងជូនដំណឹងអំពីកាលបរិច្ឆេទ នៃសវនាការដែលធ្វើឡើង ដោយអនុលោមតាមបញ្ញត្តិមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## នាពេលសវនាការ

១-ជនជាប់ចោទឈ្មោះ [redacted] សុភាព បានឆ្លើយសារភាពនាពេលសវនាការថា៖ ដីកំពុងមានទំនាស់ គឺខ្លួនបានទទួលពីឪពុកម្តាយរបស់ខ្លួនតាំងពីឆ្នាំ១៩៩៩ មកម្ល៉េះ មានទំហំ ០៥ហិចតា មានទីតាំងស្ថិតនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ បន្ទាប់ពីបានទទួលដីខាងលើ ខ្លួនបានចូលទៅកាន់កាប់ និងអាស្រ័យផលជារៀងរាល់ឆ្នាំ ដោយពុំនរណាមកហាមឃាត់នោះទេ ក្រោយមកនៅក្នុងឆ្នាំ២០០៩ ក៏មានក្រុមហ៊ុន **អង្គរស៊ូតើ** ចូលមក ខ្លួនក៏បានផ្អាកការកាន់កាប់ និងអាស្រ័យផលសិន រងចាំដំណោះស្រាយពីក្រុមហ៊ុន ។ ក្រោយមកក្រុមហ៊ុន **អង្គរស៊ូតើ** ក្ស័យធន ពេលនោះមេភូមិពុលបានប្រាប់ខ្លួនឱ្យចូលទៅកាន់កាប់ និងអាស្រ័យផលវិញ ពេលនោះខ្លួនក៏បានចូលទៅកាន់កាប់ និងអាស្រ័យផល លើដីរបស់ខ្លួនជាថ្មីម្តងទៀត រហូតមកដល់សព្វថ្ងៃ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើ សំរោង ចំនួន០៣រូប មានឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] សារើន និងឈ្មោះ **ប៊ុនធឿន** បានទៅចុះចុច **ជីភីអេស** (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង បានចុច **ជីភីអេស** លើដីរបស់ខ្លួនរួចមកគាត់បានចេញ នូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏ដាក់បណ្តឹងសុំកិច្ចអន្តរាគមន៍មកសាលាខេត្តឧត្តរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់មកឱ្យពួកខ្លួន ហើយក្នុងបណ្តឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផល គូសដោយរដ្ឋបាលព្រៃឈើសំរោងយោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបាន បង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយកទៅសះសេរបន្ថែមអ្វីនោះទេ ដោយពួកខ្លួនទទួលបានយ៉ាងមិច ពួកខ្លួនដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើសំរោង ប្រាកដមែន ។ រហូតមកដល់បច្ចុប្បន្ននេះ ដីដែលខ្លួនបានកាន់កាប់កន្លងមកនេះ គឺខ្លួនបានឈប់អាស្រ័យផលយូរណាស់មកហើយ និងបានប្រគល់ឱ្យរដ្ឋវិញអស់ហើយ ហើយឈ្មោះ [redacted] រ៉ាត គឺគាត់បានទទួលមរណភាព បាត់ហើយ ។

២-ជនជាប់ចោទឈ្មោះ [redacted] ថារ៉ា បានឆ្លើយសារភាពនាពេលសវនាការថា៖ ដីកំពុងមានទំនាស់ គឺខ្លួនបានចូលកាន់កាប់ និងអាស្រ័យផលតាំងពីឆ្នាំ១៩៩៩មកម្ល៉េះ ដោយពុំនរណាមកហាមឃាត់នោះទេ ក្រោយមកក៏មានក្រុមហ៊ុន **អង្គរស៊ូតើ** ចូលមកកាន់កាប់លើដីរបស់ខ្លួន ពេលនោះខ្លួនក៏មានផ្អាកការកាន់កាប់ បន្ទាប់ពីក្រុមហ៊ុន **អង្គរស៊ូតើ** ចូលមកកាន់កាប់លើដីខ្លួន មានចំនួន០៥ឆ្នាំ ក្រុមហ៊ុន **អង្គរស៊ូតើ** ក៏បានត្រឡប់ទៅវិញ ពេលនោះលោកមេឃុំសំរោង ឈ្មោះ [redacted] បឿង បានប្រាប់ឱ្យខ្លួនចូលទៅកាន់កាប់ លើដីរបស់ខ្លួន ពេលនោះខ្លួនក៏ចូលទៅកាន់កាប់ជាថ្មីម្តងទៀត ហើយក្នុងពេលដែលខ្លួនកាន់កាប់ដីខាងលើ គឺមិនមានអាជ្ញាធរ ឬនរណាម្នាក់មកហាមឃាត់ខ្លួននោះទេ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង ចំនួន០៣រូប មានឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] សារើន និងឈ្មោះ ប៊ុនធឿន បានទៅចុះ **ជីភីអេស** (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោងបានចុច **ជីភីអេស** លើដីរបស់ខ្លួនរួចមក

គាត់បានចេញនូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏ដាក់បណ្ដឹងសុំកិច្ចអន្តរាគមន៍ មកសាលាខេត្តឧត្ដរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់មកឱ្យពួក ខ្លួនហើយក្នុងបណ្ដឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង យោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយក ទៅសរសេរបន្ថែមអ្វីនោះទេ ដោយពួកខ្លួនទទួលបានយ៉ាងមិច ពួកនាងខ្ញុំដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញ ទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើ ប្រាកដមែន ។ រហូតមកដល់បច្ចុប្បន្ននេះ ដីដែលខ្លួនបានកាន់កាប់កន្លងមកនេះ គឺខ្លួនបានឈប់អាស្រ័យផលយូរណាស់មកហើយ និងបានប្រគល់ឱ្យរដ្ឋវិញអស់ហើយ ហើយឈ្មោះ[redacted] រ៉ាត គឺគាត់បានទទួលមរណភាព បាត់ហើយ ។

៣-ជនជាប់ចោទឈ្មោះ [redacted] ឡុញ បានឆ្លើយសារភាពនាពេលសវនាការថា៖ ដីកំពុងមានទំនាស់ ខ្លួនបានទទួលពីលោកមេភូមិដូនដែន ឈ្មោះ យូរ មានទំហំ០៥ហិចតា មានទីតាំងស្ថិតនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្ដរមានជ័យ បន្ទាប់ពីបានទទួលដីខាងលើ ខ្លួនបានចូលទៅកាន់កាប់ និងអាស្រ័យផលជារៀងរាល់ឆ្នាំ ដោយពុំនរណាមកហាមឃាត់នោះទេ ក្រោយមកនៅក្នុងឆ្នាំ២០០៨ ក៏មានក្រុមហ៊ុន **អង្គរស៊្វីតេី** ចូលមកខ្លួនក៏បានផ្អាកការកាន់កាប់ និងអាស្រ័យផលសិន រងចាំដំណោះស្រាយពីក្រុមហ៊ុន ។ ក្រោយមកក្រុមហ៊ុន **អង្គរស៊្វីតេី** ក្ស័យធន ពេលនោះមេភូមិបានប្រាប់ខ្លួនឱ្យចូលទៅកាន់កាប់ និងអាស្រ័យផលវិញ ពេលនោះខ្លួនក៏បានចូលទៅកាន់កាប់ និងអស្រ័យផលលើដីរបស់ខ្លួន ជាថ្មីម្ដងទៀត រហូតមកដល់សព្វថ្ងៃ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង ចំនួន០៣រូប មានឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] សារើន និងឈ្មោះ **ប៊ុនធឿន** បានទៅចុះចុច **ជីភីអេស** (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង បានចុចជីភីអេសលើដីរបស់ខ្លួនរួចមក គាត់បានចេញនូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏ដាក់បណ្ដឹងសុំកិច្ចអន្តរាគមន៍ មកសាលាខេត្តឧត្ដរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់មកឱ្យពួកខ្លួន ហើយក្នុងបណ្ដឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផល គូសដោយរដ្ឋបាលព្រៃឈើសំរោងយោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូស ដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយកទៅសរសេរបន្ថែមអ្វីនោះទេ ដោយពួកខ្លួនទទួលបានយ៉ាងមិច ពួកខ្លួនដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើសំរោង ប្រាកដមែន ។ រហូតមកដល់បច្ចុប្បន្ននេះ ដីដែលខ្លួនបានកាន់កាប់កន្លងមកនេះ គឺខ្លួនបានឈប់អាស្រ័យផលយូរណាស់មកហើយ និងបានប្រគល់ឱ្យរដ្ឋវិញអស់ហើយ ហើយឈ្មោះ[redacted] រ៉ាត គឺគាត់បានទទួលមរណភាព បាត់ហើយ ។

៤-ជនជាប់ចោទឈ្មោះ ម៉ៃ ពេកបានឆ្លើយសារភាពនាពេលសវនាការថា៖ ដីកំពុងមានទំនាស់ ខ្លួនបានទទួលពីឪពុកម្ដាយចែកមកឱ្យខ្លួនតាំងពីអំឡុងឆ្នាំ១៩៩៩ មានទំហំ ០៥ហិចតា មានទីតាំងស្ថិតនៅភូមិត្រពាំងវែង សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្ដរមានជ័យ បន្ទាប់ពីបានទទួលដីខាងលើ ខ្លួនបានចូលទៅកាន់កាប់ និងអាស្រ័យផលជារៀងរាល់ឆ្នាំ ដោយពុំនរណាមកហាមឃាត់ នោះទេ ក្រោយមកនៅក្នុងឆ្នាំ២០០៩ ក៏មានក្រុមហ៊ុន **អង្គរស៊្វីតេី** ចូលមកតែមិនបានប៉ះពាល់លើដី

របស់ខ្លួននោះទេ ។ ដូច្នេះខ្លួននៅតែបន្តកាន់កាប់ និងអាស្រ័យផលនៅលើដីរបស់ខ្លួន រៀងរាល់ឆ្នាំរហូតមកដល់សព្វថ្ងៃ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង ចំនួន០៣រូប មានឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] សារើន និងឈ្មោះ ប៊ុនធឿន បានទៅចុះចុច ជីភីអេស (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង បានចុចជីភីអេសលើដីរបស់ខ្លួនរួចមក គាត់បានចេញនូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏ដាក់បណ្ដឹងសុំកិច្ចអន្តរាគមន៍មកសាលាខេត្តឧត្តរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់មកឱ្យពួកខ្លួន ហើយក្នុងបណ្ដឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផល គូសដោយរដ្ឋបាលព្រៃឈើសំរោងយោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផល គូសដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយកទៅសរសេរបន្ថែមអ្វីនោះទេ ដោយពួកខ្លួនទទួលបានយ៉ាងមិច ពួកខ្លួនដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើ សំរោងប្រាកដមែន ។ រហូតមកដល់បច្ចុប្បន្ននេះ ដីដែលខ្លួនបានកាន់កាប់កន្លងមកនេះ គឺខ្លួនបានឈប់អាស្រ័យផលយូរណាស់មកហើយ និងបានប្រគល់ឱ្យរដ្ឋវិញអស់ហើយ ហើយឈ្មោះ [redacted] **វ៉ាត** គឺគាត់បានទទួលមរណភាព បាត់ហើយ ។

៥-ជនជាប់ចោទឈ្មោះ [redacted] គក់ បានឆ្លើយសារភាពនាពេលសវនាការថា៖ ដីកំពុងមានទំនាស់ ខ្លួនបានទទួលមកពីការបែងចែកពីលោកមេភូមិឈ្មោះ [redacted] សាវឿន នៅក្នុងអំឡុងឆ្នាំ១៩៩៩ ទំហំ ០២ហិចតា បន្ទាប់ពីបានទទួលដីខាងលើខ្លួនបានចូលទៅកាន់កាប់ និងអាស្រ័យផលជារៀងរាល់ឆ្នាំ ដោយពុំនរណាមកហាមឃាត់នោះទេ ក្រោយមកនៅក្នុងឆ្នាំ២០០៩ ក៏មានក្រុមហ៊ុន **អង្គរស្ទ៊ីតើ** ចូលមកកាន់កាប់លើដីរបស់ខ្លួន ពេលនោះខ្លួនក៏មានផ្អាកការកាន់កាប់សិន រកចាំដំណោះស្រាយពីក្រុមហ៊ុន ។ បន្ទាប់ពីក្រុមហ៊ុន **អង្គរស្ទ៊ីតើ** ចូលមកកាន់កាប់លើដីខ្លួន មានចំនួន០៥ឆ្នាំ ក្រុមហ៊ុន **អង្គរស្ទ៊ីតើ** ក៏បានត្រឡប់ទៅវិញ ។ ពេលនោះខ្លួនក៏ចូលទៅកាន់កាប់ និងអាស្រ័យផលលើដីរបស់ខ្លួនជាថ្មីម្ដងទៀត ហើយក្នុងពេលដែលខ្លួនកាន់កាប់ដីខាងលើ គឺមិនមានអាជ្ញាធរ ឬនរណាម្នាក់មកហាមឃាត់ខ្លួននោះទេ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង ចំនួន០៣រូប មានឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] សារើន និងឈ្មោះ **ប៊ុនធឿន** បានទៅចុះចុច ជីភីអេស (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោងបានចុច ជីភីអេស លើដីរបស់ខ្លួនរួចមក គាត់បានចេញនូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏ដាក់បណ្ដឹងសុំកិច្ចអន្តរាគមន៍មកសាលាខេត្តឧត្តរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់មកឱ្យពួកខ្លួន ហើយក្នុងបណ្ដឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោងយោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយកទៅសរសេរបន្ថែមអ្វីនោះទេ ដោយពួកខ្លួនទទួលបានយ៉ាងមិច ពួកខ្លួនដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើសំរោង ប្រាកដមែន ហើយឈ្មោះ [redacted] **វ៉ាត** គឺគាត់បានទទួលមរណភាព បាត់ហើយ ។



Scanned with CamScanner

៦-ជនជាប់ចោទឈ្មោះ [redacted] លីន បានឆ្លើយសារភាពនាពេលសវនាការថា៖ ដីកំពុងមានទំនាស់ គឺខ្លួនបានចូលកាន់កាប់ និងអាស្រ័យផលតាំងពីឆ្នាំ១៩៩៩ មកម្ល៉េះ មានទំហំ ០៤ហិចតា មានទីតាំងស្ថិតនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ បន្ទាប់មកខ្លួនបានចូលទៅកាន់កាប់ និងអាស្រ័យផលដីខាងលើ ជារៀងរាល់ឆ្នាំ ដោយពុំនរណាមកហាមឃាត់នោះទេ ។ ក្រោយមកនៅក្នុងឆ្នាំ២០០៩ ក៏មានក្រុមហ៊ុន **អង្គរស៊ូតើ** ចូលមកខ្លួនក៏បានផ្អាកការកាន់កាប់ និងអស្រ័យផលសិន រង់ចាំដំណោះស្រាយពីក្រុមហ៊ុន ។ ក្រោយមកក្រុមហ៊ុន **អង្គរស៊ូតើ** ក្ស័យធន ពេលនោះមេភូមិពុលបានប្រាប់ ខ្លួនឱ្យចូលទៅកាន់កាប់ និងអាស្រ័យផលវិញ ពេលនោះខ្លួនក៏បានចូលទៅកាន់កាប់ និងអាស្រ័យផល លើដីរបស់ខ្លួនជាថ្មីម្តងទៀតរហូតមកដល់សព្វថ្ងៃ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង ចំនួន០៣រូប មានឈ្មោះ [redacted]សុភា, ឈ្មោះ [redacted] សាវើន និងឈ្មោះ **ប៊ុនធឿន** បានទៅចុះចុច ជីភីអេស (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង បានចុច ជីភីអេស លើដីរបស់ខ្លួនរួចមក គាត់បានចេញនូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏ដាក់បណ្តឹងសុំកិច្ចអន្តរាគមន៍ មកសាលាខេត្តឧត្តរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់មកឱ្យពួកខ្លួន ហើយក្នុងបណ្តឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្ក បង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោងយោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែល ពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយកទៅសរសេរបន្ថែមអ្វីនោះទេ ដោយពួកខ្លួនទទួលបានយ៉ាងមិច ពួកខ្លួនដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផល គូសដោយរដ្ឋបាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើសំរោង ប្រាកដមែន ហើយឈ្មោះ [redacted] វ៉ាត គឺគាត់បានទទួលមរណភាព បាត់ហើយ ។

៧-ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន បានឆ្លើយសារភាពនាពេលសវនាការថា៖ ដីកំពុងមានទំនាស់ គឺខ្លួនបានទទួលពីឪពុកម្តាយក្នុងអំឡុងឆ្នាំ១៩៩៩ មានទំហំ ០២ហិចតា មានទីតាំងស្ថិតនៅភូមិត្រពាំងវែង សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ បន្ទាប់ពីខ្លួនបានទទួលដី ខាងលើរួចមកខ្លួនបានចូលកាន់កាប់ និងអាស្រ័យផលជារៀងរាល់ឆ្នាំ ដោយពុំមាននរណាមកហាមឃាត់នោះទេ ។ ក្រោយមកក៏មានក្រុមហ៊ុន **អង្គរស៊ូតើ** ចូលមកខ្លួនក៏បានផ្អាកការកាន់កាប់ និងអាស្រ័យផលសិន រង់ចាំដំណោះស្រាយពីក្រុមហ៊ុន ។ ក្រោយមកក្រុមហ៊ុន **អង្គរស៊ូតើ** ក្ស័យធន ខ្លួនក៏បានចូលទៅកាន់កាប់ និងអាស្រ័យផលជាថ្មីម្តងទៀត រហូតមកដល់សព្វថ្ងៃ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង ចំនួន០៣រូប មានឈ្មោះ [redacted] សុភា, ឈ្មោះ [redacted]សាវើន និងឈ្មោះ **ប៊ុនធឿន** បានទៅចុះចុច ជីភីអេស (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង បានចុច ជីភីអេស លើដីរបស់ខ្លួនរួចមក គាត់បានចេញនូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏ដាក់បណ្តឹងសុំកិច្ចអន្តរាគមន៍ មកសាលាខេត្តឧត្តរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់ឱ្យពួកខ្លួន ហើយក្នុងបណ្តឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផល គូសដោយរដ្ឋបាលព្រៃឈើសំរោងយោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយកទៅសរសេរបន្ថែមអ្វីនោះទេ ដោយពួកខ្លួនទទួលបានយ៉ាងមិច ពួកខ្លួនដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋ



Scanned with CamScanner

បាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើសំរោង ប្រាកដមែន ហើយឈ្មោះ [redacted] រ៉ាត គឺគាត់បានទទួលមរណភាព បាត់ហើយ ។

៨-ជនជាប់ចោទឈ្មោះ [redacted] ហៀប បានឆ្លើយសារភាពនាពេលសវនាការថា៖ ដីកំពុងមានទំនាស់ គឺខ្លួនបានទទួលបន្តពីឪពុកម្ដាយក្នុងឆអំឡុងឆ្នាំ១៩៩៩ ដីមានទំហំ ០៣ហិចតា មានទីតាំងស្ថិតនៅភូមិខ្ទុំ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។ បន្ទាប់ពីខ្លួនបានទទួលដីខាងលើរួចមក ខ្លួនបានចូលកាន់កាប់ និងអាស្រ័យផលជារៀងរាល់ឆ្នាំ ដោយពុំមាននរណាមកហាមឃាត់នោះទេ ។ ក្រោយ**អង្គរស៊្វីតើ** មកក៏មានក្រុមហ៊ុន ចូលមកខ្លួនក៏បានផ្អាកការកាន់កាប់ និងអស្រ័យផលសិន រងចាំដំណោះស្រាយពីក្រុមហ៊ុន ។ ក្រោយមកក្រុមហ៊ុន **អង្គរស៊្វីតើ** ក្ស័យធនពេលនោះខ្លួនក៏បានចូលទៅកាន់កាប់ និងអាស្រ័យផលជាថ្មីម្ដងទៀតរហូតមកដល់សព្វថ្ងៃ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង ចំនួន០៣រូប មានឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] សារឿន និងឈ្មោះ **ប៊ុនធឿន** បានទៅចុះចុច ជីភីអេស (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង បានចុច ជីភីអេស លើដីរបស់ខ្លួនរួចមក គាត់បានចេញនូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏ដាក់បណ្ដឹង សុំកិច្ចអន្តរាគមន៍មកសាលាខេត្តឧត្តរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់មកឱ្យពួកខ្លួន ហើយក្នុងបណ្ដឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោងយោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយកទៅសរសេរបន្ថែមអ្វីនោះទេ ដោយពួកខ្ញុំទទួលបានយ៉ាងមិច ពួកខ្លួនដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញទីតាំង និងដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើសំរោង ប្រាកដមែន ហើយឈ្មោះ [redacted] រ៉ាត គឺគាត់បានទទួលមរណភាព បាត់ហើយ ។

៩-ក្រឡាបញ្ជីអានអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] រ៉ាត បានឆ្លើយសារភាពនាថា៖ ដីកំពុងមានទំនាស់ គឺខ្លួនបានទទួលពីបែងចែករបស់លោកមេឃុំខ្ទុំ ឈ្មោះ [redacted] ដោង មានទំហំ ០៥ហិចតា មានទីតាំងស្ថិតនៅភូមិខ្ទុំ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ នៅក្នុងឆ្នាំ១៩៩៩ បន្ទាប់ពីខ្លួនបានទទួលដីខាងលើរួចមក ខ្លួនបានចូលកាន់កាប់ និងអាស្រ័យផល ជារៀងរាល់ឆ្នាំ ដោយមានពុំនរណាមកហាមឃាត់នោះ ក្រោយមកក៏មានក្រុមហ៊ុន **អង្គរស៊្វីតើ** ចូលមកខ្លួនក៏បានផ្អាកការកាន់កាប់ និងអាស្រ័យផលសិន រងចាំដំណោះស្រាយពីក្រុមហ៊ុន ។ ក្រោយមកក្រុមហ៊ុន **អង្គរស៊្វីតើ** ក្ស័យធន ពេលនោះខ្លួនក៏បានចូលទៅកាន់កាប់ និងអាស្រ័យផលជាថ្មីម្ដងទៀត រហូតមកដល់សព្វថ្ងៃ ។ ក្រោយមកអំឡុងខែឧសភា ឆ្នាំ២០២១ ខាងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង ចំនួន០៣រូប មានឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] សារិន និងឈ្មោះ **ប៊ុនធឿន** បានទៅចុះចុច ជីភីអេស (GPS) ជូនពួកខ្លួន ។ បន្ទាប់ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើសំរោង បានចុច ជីភីអេស លើដីរបស់ខ្លួនរួចមក គាត់បានចេញនូវគំនូសប្លង់បង្ហាញទីតាំងដីមួយមកឱ្យពួកខ្លួន ។ បន្ទាប់ពីពួកខ្លួនបានគំនូសប្លង់ខាងលើរួចមក ពួកខ្លួនក៏បណ្ដឹងសុំកិច្ចអន្តរាគមន៍ មកសាលាខេត្តឧត្តរមានជ័យ ដើម្បីស្នើសុំឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់មកឱ្យពួកខ្លួន ហើយក្នុងដាក់បណ្ដឹងសុំកិច្ចអន្តរាគមន៍ ពួកខ្លួនក៏បានដាក់បញ្ចូលនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោងយោងជាមួយផងដែរ ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផល គូសដោយរដ្ឋបាលព្រៃឈើសំរោង ដែលពួកខ្លួនបានដាក់ទៅនោះ គឺពួកខ្លួនមិនយកទៅ



Scanned with CamScanner

សរសេរបន្ថែមអ្វីនោះទេ ដោយពួកខ្លួនទទួលបានយ៉ាងមិច ពួកខ្លួនដាក់យ៉ាងនោះ ហើយឯកសារគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយរដ្ឋបាលព្រៃឈើសំរោង គឺពួកខ្លួនបានទទួលពីរដ្ឋបាលព្រៃឈើសំរោងប្រាកដមែន ហើយឈ្មោះ [redacted] វ៉ាត គឺគាត់បានទទួលមរណភាព បាត់ហើយ ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខែម បានឆ្លើយបំភ្លឺថា៖ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ លោកនាយខណ្ឌរដ្ឋបាលព្រៃឈើ បានចូលរួមប្រជុំដោះស្រាយវិវាទដីធ្លីនៅសាលប្រជុំនៃសាលាខេត្តឧត្តរមានជ័យ ។ បន្ទាប់ពីលោកនាយខណ្ឌរដ្ឋបាលព្រៃឈើ បានចូលរួមប្រជុំរួចមក គាត់ក៏ទទួលបានឯកសារបណ្តឹងសុំកិច្ចអន្តរាគមន៍ពីអភិបាលរងខេត្តឧត្តរមានជ័យ ដែលបណ្តឹងអន្តរាគមន៍ខាងលើធ្វើឡើងដោយ ប្រជាពលរដ្ឋចំនួន០៩រូប ទី១.ឈ្មោះ [redacted] ថាវ៉ា, ទី២.ឈ្មោះ [redacted] គក់, ទី៣. ឈ្មោះ [redacted] លីន, ទី៤.ឈ្មោះ [redacted] ឡុង, ទី៥.ឈ្មោះ [redacted] ពេក, ទី៦.ឈ្មោះ [redacted] ញ៉ាន, ទី៧.ឈ្មោះ [redacted] វ៉ាត, ទី៨. ឈ្មោះ [redacted] ហៀប និងទី៩.ឈ្មោះ [redacted] សុភាព ។ បន្ទាប់ពីលោកនាយកខណ្ឌរដ្ឋបាលព្រៃ បានទទួលបណ្តឹងសុំកិច្ចអន្តរាគមន៍រួចមក គាត់បានប្រាប់ខ្លួនពេលនោះខ្លួនបានពិនិត្យលើបណ្តឹងសុំកិច្ចអន្តរាគមន៍នោះ ឃើញថាប្រជាពលរដ្ឋទាំង ០៩រូប បានយោងនូវគំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្កបង្កើនផលគូសដោយនាយផ្នែករដ្ឋបាលព្រៃឈើសំរោង ។ ចំពោះគំនូសបង្ហាញទីតាំង និងទំហំដីដែលប្រជាពលរដ្ឋ បានយកមកធ្វើជាឯកសារយោង នោះគឺផ្នែករដ្ឋបាលព្រៃសំរោងរបស់ខ្លួន មិនបានចេញឱ្យពួកគាត់ទាំង ០៩រូបនោះ ដោយហេតុថា ផ្នែករដ្ឋបាលព្រៃឈើ មិនមានសមត្ថកិច្ចក្នុងការគូសគំនូសបង្ហាញទីតាំង និងទំហំដី ជូនប្រជាពលរដ្ឋនោះទេ ។

១១-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានដេញដោលនាពេលសវនាការ ,ក្រោយពីបានស្តាប់ចម្លើយសារភាពជនជាប់ចោទខាងលើ, ក្រោយពីបានស្តាប់អំណាងចម្លើយជនជាប់ចោទ, ក្រោយពីបានស្តាប់ចម្លើយបំភ្លឺដើមបណ្តឹងរដ្ឋប្បវេណី និងក្រោយពីបានពិនិត្យឯកសារភស្តុតាងផ្សេងៗ ឃើញថា៖ ពិតជាមានករណី "ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ញុញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លីន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន, ជនជាប់ចោទឈ្មោះ [redacted] ហៀប និងជនជាប់ចោទឈ្មោះ [redacted] វ៉ាត ពិតប្រាកដមែន ។ ដូចនេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខៈ ១២៧ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ទុកនៅដដែល និងសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទដាក់ពន្ធនាគារតាមកំណត់ច្បាប់ ។

១២-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡុញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លីន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន, ជនជាប់ចោទឈ្មោះ [redacted] ហៀប និងជនជាប់ចោទឈ្មោះ [redacted] វ៉ាត បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ឡើយ ដោយពួកគាត់ដាក់ពាក្យបណ្តឹងទៅសាលាខេត្តដើម្បីទាមទារដីរបស់ពួកគាត់ត្រឡប់មកវិញ ដោយសុំឱ្យកាត់ឆ្វៀលដីជាមួយក្រុមហ៊ុន អង្គរស៊្មីតេ ប៉ុណ្ណោះ ។ ចំណែកគំនូសបង្ហាញទីតាំងដីនេះ គឺពួកគាត់មិនបានគូសដោយខ្លួននោះទេ ដោយសារមានការភ័ស្តច្រលំ និងខ្វះការយល់ដឹងនៅលើគំនូសនេះទើបពួកគាត់ភ្ជាប់ជាឯកសារយោង នៅក្នុងពាក្យសុំអន្តរាគមន៍សុំបែងចែកតែម្តងទៅ ដូចនេះក្នុងនាមខ្លួនជាមេធាវីការសិទ្ធិឱ្យជនជាប់ចោទខាងលើ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ។

១៣-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡុញ និងជនជាប់ចោទឈ្មោះ [redacted] គក់ ធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្លួនក្តីខ្លួនមិនមែនជាអ្នកគូសគំនូសបង្ហាញទីតាំងដីនៅលើឯកសារនេះទេ ដោយពួកគាត់ដាក់ពាក្យបណ្តឹងដើម្បីទាមទារដីរបស់ពួកគាត់ត្រឡប់មកវិញប៉ុណ្ណោះ ដូចក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥០ នៃក្រមព្រហ្មទណ្ឌ ។

១៤-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡុញ, ជនជាប់ចោទឈ្មោះ [redacted], ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លើន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន, ជនជាប់ចោទឈ្មោះ [redacted] ហៀប សំណូមពរ៖ សុំឱ្យតុលាការមេត្តាលើកលែងទោសឱ្យខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តអំពើដូចការចោទប្រកាន់នោះទេ ។

-ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] រ៉ាត

-ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធក្នុងសំណុំរឿង

-តុលាការក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តឧត្តរមានជ័យ
## យល់ឃើញថា

១-ពិតជាកើតមានឡើងនូវអំពើ "ក្លែងបន្លំឯកសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ប្រព្រឹត្តនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡុញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លើន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន, ជនជាប់ចោទឈ្មោះ [redacted] ហៀប និងជនជាប់ចោទឈ្មោះ [redacted] រ៉ាត ពិតប្រាកដមែន ។

២-តាមអង្គហេតុដែលចោទប្រកាន់, តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាព, តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ឡុញ, តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ពេក, តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] គក់, តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] លើន, តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន, តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ហៀប, តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] រ៉ាត, តាមចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខែម និងភស្តុតាងនានា ឃើញថា: ជនជាប់ចោទខាងលើ ពិតជាបានដាក់ពាក្យបណ្តឹងអន្តរាគមន៍ ដោយមានភ្ជាប់ឯកសារមួយដែលមានចំណងជើងថា គំនូសបង្ហាញទីតាំង និងទំហំដីដែលពលរដ្ឋបានបង្ក

បង្កើនផលគូសដោយផ្នែករដ្ឋបាលព្រៃឈើសំរោង ដោយឯកសារនេះមានភាពមិនប្រក្រតី គ្មានហត្ថលេខា និងគ្មានលេខរដ្ឋបាល ពិតប្រាកដមែន ម្យ៉ាងទៀតឯកសារគំនូសបង្ហាញទីតាំង និងទំហំដីខាងលើនេះ គឺមិនបានគូសដោយផ្នែករដ្ឋបាលព្រៃឈើសំរោងនោះទេ ដោយមិនបានដឹងថា ជនជាប់ចោទយកឯកសារនេះមកពីណា ពិតប្រាកដមែន ។

៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡុញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លើន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន, ជនជាប់ចោទឈ្មោះ [redacted] ហៀប និងជនជាប់ចោទឈ្មោះ [redacted] វ៉ាត គឺជាបទល្មើស "ក្លែងបន្លំឯកសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ប្រព្រឹត្តនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

៤-ពេលប្រព្រឹត្តបទល្មើសជនជាប់ចោទជានីតិជន មានស្មារតីពេញលេញ ក្នុងការទទួលខុសត្រូវនូវអំពើល្មើសច្បាប់ដែលខ្លួនបានប្រព្រឹត្ត និងមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវទោសព្រហ្មទណ្ឌ ហើយអំពើនេះបានធ្វើប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ,សណ្តាប់ធ្នាប់ ,សន្តិសុខសង្គម និង ជាអំពើដែលច្បាប់បានហាមប្រាមយ៉ាងដាច់ខាត ដែលតម្រូវឱ្យផ្តន្ទាទោស តុលាការគប្បីពិចារណាផ្តន្ទាទោសច្បាប់ ។

៥-ផ្អែកតាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការឃើញថា អង្គហេតុនេះជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡុញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់ , ជនជាប់ចោទឈ្មោះ [redacted] លើន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន, ជនជាប់ចោទឈ្មោះ [redacted] ហៀប និងជនជាប់ចោទឈ្មោះ [redacted] វ៉ាត ពិតជាបានប្រព្រឹត្តអំពើ "ក្លែងបន្លំឯកសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ពិតប្រាកដមែន ដែលអំពើនេះត្រូវបានច្បាប់កំណត់ថាជាបទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ តំណាងអយ្យការសូមរក្សាការចោទប្រកាន់ទុកជាបានការដដែល ដោយប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទដាពន្ធនាគារតាមច្បាប់ ។

៦-នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខែម បានទាមទារសំណងជម្ងឺចិត្តសរុបចំនួន ២០,០០០,០០០ រៀល គប្បីតុលាការលើកយកសំណងមកពិចារណា និងសម្រេចតាមព្យសនកម្មដែលកើតឡើងឱ្យបានសមរម្យ ។

៧-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡុញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លើន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន, ជនជាប់ចោទឈ្មោះ [redacted] ហៀប បានបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] វ៉ាត គឺបានទទួលមរណភាពបាត់ហើយ ដូចនេះគប្បីតុលាការសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] វ៉ាត រួចផុតពីបទចោទប្រកាន់ ពីបទ "ក្លែងបន្លំឯកសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" តាមមាត្រា ៧ ការរលត់នៃបណ្តឹងអាជ្ញា (មរណភាពនៃជនល្មើស) នៃក្រមនីតិវិធី នៃព្រះរាជាណាចក្រកម្ពុជា ។

៨-ក្រោយពីតុលាការបានពិនិត្យលើចម្លើយរបស់ជនជាប់ចោទ, ការពិនិត្យភស្តុតាងគ្រប់ដំណាក់កាល និងផ្ទៀងផ្ទាត់យ៉ាងលម្អិតរួចមកឃើញថា: នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡុញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លើន,



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted]ញ៉ាន, ជនជាប់ចោទឈ្មោះ [redacted] ហៀប បានសារភាពនូវទោសកំហុសរបស់ខ្លួន និងហ៊ានទទួលខុសត្រូវលើទង្វើរបស់ខ្លួនដែលប្រព្រឹត្ត ហើយការដាក់ពាក្យបណ្ដឹងអន្តរាគមន៍របស់ជនជាប់ចោទខាងលើនេះ គឺក្នុងគោលបំណងទាមទារដីរបស់ខ្លួនមកវិញប៉ុណ្ណោះ រហូតមកដល់បច្ចុប្បន្ននេះជនជាប់ចោទខាងលើ ក៏បានចាកចេញពីដីខាងលើនេះ និងបានប្រគល់ដីឲ្យទៅរដ្ឋវិញរួចហើយ ម្យ៉ាងទៀតផ្អែកតាមលក្ខខណ្ឌបុគ្គលរបស់ជនជាប់ចោទ គឺខ្វះការយល់ដឹងមិនបានរៀនសូត្រជ្រៅជ្រះផងដែរ គប្បីតុលាការសម្រេចព្យួរទោស ដើម្បីផ្ដល់ឱកាសដល់ជនជាប់ចោទកែប្រែខ្លួនជាប្រជាពលរដ្ឋល្អវិញ តាមមាត្រា ៩៣,មាត្រា ៩៤,មាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

៩-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ៖

ក.ឈ្មោះ[redacted]សុភាព ភេទស្រី កើតឆ្នាំ១៩៨៥ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ខ.ឈ្មោះ[redacted]ថាវ៉ា ភេទស្រី អាយុ៥៩ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

គ.ឈ្មោះ[redacted]ឡូញ ភេទប្រុស អាយុ៥៧ឆ្នាំ (សាវតាជាតិដូចខាងលើ)

ឃ.ឈ្មោះ[redacted] ពេក ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ង.ឈ្មោះ [redacted] គក់ ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ច.ឈ្មោះ[redacted] លើន ភេទស្រី អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ឆ.ឈ្មោះ[redacted] ញ៉ាន ភេទប្រុស អាយុ៥៩ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ជ.ឈ្មោះ [redacted] ហៀប ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ពីបទ "ក្លែងបន្លំឯកសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ប្រព្រឹត្តនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្ដន្ទាទោសតាមមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

និងប្រកាសទោសអនុវត្ត តាមមាត្រា ៣៨, មាត្រា ៩៧ និងមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ ។

**ហេតុដូច្នេះ**

**សាលាដំបូងខេត្តឧត្តរមានជ័យ**

**សម្រេច ៖**

I/ ផ្ដន្ទាទោសលើជនជាប់ចោទ៖

ក.ឈ្មោះ[redacted]សុភាព ភេទស្រី កើតឆ្នាំ១៩៨៥ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ខ.ឈ្មោះ[redacted] ថាវ៉ា ភេទស្រី អាយុ៥៩ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

គ.ឈ្មោះ[redacted] ឡូញ ភេទប្រុស អាយុ៥៧ឆ្នាំ (សាវតាជាតិដូចខាងលើ)

ឃ.ឈ្មោះ[redacted] ពេក ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ង.ឈ្មោះ [redacted] គក់ ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ច.ឈ្មោះ[redacted] លើន ភេទស្រី អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ឆ.ឈ្មោះ [redacted] ញ៉ាន ភេទប្រុស អាយុ៥៩ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ជ.ឈ្មោះ[redacted]ហៀប ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

- ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេល ០៥ឆ្នាំ (ប្រាំឆ្នាំ) ដែលទោសនេះត្រូវព្យួរក្នុងលក្ខខណ្ឌព្យួរទោសធម្មតា ពីបទ "ក្លែងបន្លំឯកសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ប្រព្រឹត្តនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ។

II/ ឱ្យជនជាប់ចោទឈ្មោះ៖

ក.ឈ្មោះ [redacted] វ៉ាត ភេទប្រុស អាយុ៥៥ឆ្នាំ សញ្ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

រួចផុតពីបទចោទលើ ពីបទ "ក្លែងបន្លំឯកសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ប្រព្រឹត្តនៅភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ។

III/ បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡាញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លីន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន និងជនជាប់ចោទឈ្មោះ [redacted] ហៀប រួមគ្នាសងសំណងជម្ងឺចិត្តចំនួន ៤,០០០,០០០ រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខែម ការទាមទារលើសពីនេះច្រាលចោល។

IV/ សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃ ព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុភាព, ជនជាប់ចោទឈ្មោះ [redacted] ថាវ៉ា, ជនជាប់ចោទឈ្មោះ [redacted] ឡាញ, ជនជាប់ចោទឈ្មោះ [redacted] ពេក, ជនជាប់ចោទឈ្មោះ [redacted] គក់, ជនជាប់ចោទឈ្មោះ [redacted] លីន, ជនជាប់ចោទឈ្មោះ [redacted] ញ៉ាន និងជនជាប់ចោទឈ្មោះ [redacted] ហៀប និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខែម និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វ៉ាត ។

-ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted] [redacted]

---

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ ព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ខេត្តឧត្តរមានជ័យ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner